**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០៩ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រើប្រាស់គណនី

## ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខជស/រកម/០១៩៨/០១ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អន្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១** : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈដែលត្រូវបានបង្កើតឡើងតាមមាត្រា៨៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដើម្បីចំណាយលើការងាររៀបចំបណ្តាញអគ្គិសនី និងការងារផ្គត់ផ្គង់តម្លើងឧបករណ៍ បរិក្ខារ ប្រព័ន្ធជូនដំណឹង ប្រព័ន្ធកាមេរ៉ាសន្តិសុខ ប្រព័ន្ធត្រួតពិនិត្យច្រកចេញ-ចូល ប្រព័ន្ធទូរទស្សន៍ខ្សែកាប បណ្តាញទិន្នន័យ ប្រព័ន្ធទូរស័ព្ទ ប្រព័ន្ធសម្លេង-រូបភាព ប្រព័ន្ធសាលសន្និសីទ និងបកប្រែភាសា ប្រព័ន្ធបញ្ចាំងរូបភាព និងបញ្ចាំងរូបភាពព័ត៌មាន ជូនអគារទីស្តីការនាយករដ្ឋមន្ត្រី និងមជ្ឈមណ្ឌលសន្និសីទអន្តរជាតិ មានទឹកប្រាក់សរុបចំនួន ១១.១៣៩.៥៨៤.៨៩ ដុល្លារអាមេរិក (ដប់មួយលានមួយរយសាមសិបប្រាំបួនពាន់ប្រាំរយប៉ែតសិបបួនដុល្លារអាមេរិក និងប៉ែតសិបប្រាំបួនសេន)។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់គ្រងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១០*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (ដើម្បីជូនជ្រាប)
- ដូចក្នុងមាត្រា ២
- ឯកសារ-កាលប្បវត្តិ